**VACCINE INFORMATION STATEMENT (សេចក្តីថ្លែងព័ត៌មានអំពីវ៉ាក់សាំង)**

# វ៉ាក់សាំង COVID-19៖
## *អ្វីដែលអ្នកត្រូវដឹង*

Many Vaccine Information Statements are available in Khmer and other languages. See www.immunize.org/vis

សេចក្តីថ្លែងការណ៍នៃព័ត៌មានអំពីវ៉ាក់សាំងជាច្រើនគឺអាចរកបានជាភាសាខ្មែរ និងភាសាផ្សេងទៀត។ ចូលមើល www.immunize.org/vis

## 1. ហេតុអ្វីត្រូវចាក់ថ្នាំវ៉ាក់សាំង?

វ៉ាក់សាំង **COVID-19** អាចបង្ការជំងឺ **COVID-19**។ ការចាក់វ៉ាក់សាំងអាចជួយកាត់បន្ថយភាពធ្ងន់ធ្ងរនៃជំងឺ COVID-19 ប្រសិនបើអ្នកឈឺ។

COVID-19 បង្កឡើងដោយវីរុសកូរ៉ូណាហៅថា SARS-CoV-2 ដែលរីកសាយភាយយ៉ាងងាយពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។ COVID-19 អាចបណ្តាលឱ្យមានជំងឺស្រាលទៅមធ្យម ក្នុងរយៈពេលតែពីរបីថ្ងៃប៉ុណ្ណោះ ឬជំងឺធ្ងន់ធ្ងរដែលតម្រូវឱ្យចូលសម្រាកពេទ្យ ការថែទាំកម្រិតខ្ពស់ ឬប្រដាប់បញ្ចូលអុកស៊ីសែនដើម្បីជួយសម្រួលដល់ការដកដង្ហើម។ COVID-19 ក៏អាចបណ្តាលឱ្យស្លាប់។

រោគសញ្ញា COVID-19 អាចលេចឡើងពី 2 ទៅ 14 ថ្ងៃ បន្ទាប់ពីការប៉ះពាល់នឹងវីរុស។ មនុស្សម្នាក់អាចមានរោគសញ្ញាស្រាល មធ្យម ឬធ្ងន់ធ្ងរ។

- រោគសញ្ញាដែលអាចកើតមានរួមមានដូចជា គ្រុនក្តៅ រងារញាក់ ក្អក ដកដង្ហើមខ្លី ឬពិបាកដកដង្ហើម អស់កម្លាំង (ល្ហិតល្ហៃ) ឈឺសាច់ដុំ ឬឈឺខ្លួន ឈឺក្បាល បាត់បង់រសជាតិឬក្លិនថ្មី ឈឺបំពង់ក តឹងច្រមុះ ឬហៀរសំបោរ ចង្អោរ ក្អួត និងរាគ។
- រោគសញ្ញាធ្ងន់ធ្ងរជាងនេះអាចរួមមានការពិបាកដកដង្ហើម ការឈឺចាប់ជាប់រហូត ឬសម្ពាធក្នុងទ្រូង ភាពច្របូកច្របល់ថ្មី អសមត្ថភាពក្នុងការភ្ញាក់ ឬនៅភ្ញាក់ និងឡើងស្លេក ប្រផេះ ឬពណ៌ខៀវលើស្បែក បបូរមាត់ ឬក្រចក (អាស្រ័យលើពណ៌ស្បែក)។

មនុស្សចាស់ និងមនុស្សដែលមានស្ថានភាពជំងឺប្រចាំកាយជាក់លាក់មួយចំនួន (ដូចជាជំងឺបេះដូង ឬសួត ឬជំងឺទឹកនោមផ្អែម) ទំនងជាឈឺខ្លាំងដោយសារជំងឺ COVID-19។

បន្ទាប់ពីជំងឺ COVID-19 មនុស្សមួយចំនួនមានជំងឺ COVID រយៈពេលយូរដែលជាជំងឺរ៉ាំរ៉ៃដែលមានរោគសញ្ញារ៉ាំរ៉ៃរយៈពេល 3 ខែ ឬយូរជាងនេះ។ រោគសញ្ញានៃជំងឺ COVID រយៈពេលវែង អាចនឹងធូរស្បើយ កាន់តែអាក្រក់ ឬនៅដដែល។

អ្នកដែលទទួលវ៉ាក់សាំង COVID-19 ថ្មីៗមានហានិភ័យទាបក្នុងការកើតមានជំងឺធ្ងន់ធ្ងរ ការចូលសម្រាកពេទ្យ និងការស្លាប់បាត់បង់ជីវិតដោយសារ COVID-19 ជាងអ្នកដែលមិនបានទទួលវ៉ាក់សាំងថ្មីៗ។ ការចាក់វ៉ាក់សាំងជំងឺ COVID-19 គឺជាមធ្យោបាយដ៏ល្អបំផុតក្នុងការបង្ការជំងឺ COVID រយៈពេលវែង។

ការចាក់វ៉ាក់សាំង COVID-19 ជួយឱ្យរាងកាយរៀនពីរបៀបការពារខ្លួនពីជំងឺ និងកាត់បន្ថយហានិភ័យនៃជំងឺធ្ងន់ធ្ងរ និងផលវិបាក។ លើសពីនេះ វ៉ាក់សាំង COVID-19 អាចផ្តល់ការការពារបន្ថែមដល់អ្នកដែលមាន COVID-19 រួចហើយ រួមទាំងការការពារពីការចូលសម្រាកពេទ្យប្រសិនបើពួកគេឆ្លង COVID-19 ម្តងទៀត។

## 2. វ៉ាក់សាំង COVID-19

ធ្វើបច្ចុប្បន្នភាពវ៉ាក់សាំង COVID-19 ឆ្នាំ 2024–2025 ត្រូវបានណែនាំសម្រាប់មនុស្សគ្រប់រូបដែលមានអាយុចាប់ពី 6 ខែឡើងទៅ។ នេះរួមទាំងអ្នកដែលមានផ្ទៃពោះ បំបៅកូនដោយទឹកដោះម្តាយ ឬអ្នកព្យាយាមមានផ្ទៃពោះឥឡូវនេះ ឬអ្នកដែលប្រហែលជាអាចមានផ្ទៃពោះនាពេលអនាគត។

វ៉ាក់សាំង COVID-19 ឆ្នាំ 2024–2025 សម្រាប់ទារក និងកុមារដែលមានអាយុ 6 ខែដល់ 11 ឆ្នាំ គឺអាចរកបានក្រោមការអនុញ្ញាតប្រើប្រាស់ក្នុងគ្រាអាសន្នពីរដ្ឋបាលចំណីអាហារ និងឱសថសហរដ្ឋអាមេរិក (FDA)។ សូមមើលតារាងសង្ខេបសម្រាប់អ្នកទទួល និងអ្នកផ្តល់ការថែទាំសម្រាប់ព័ត៌មានបន្ថែម។

សម្រាប់មនុស្សដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ វ៉ាក់សាំង COVID-19 ឆ្នាំ 2024–2025 ដែលបានផលិតដោយ ModernaTX, Inc. ឬ Pfizer, Inc. ត្រូវបានអនុម័តដោយ FDA។

វ៉ាក់សាំង Novavax COVID-19 Vaccine Adjuvanted (2024-2025 Formula) អាចប្រើបានក្រោមការអនុញ្ញាតប្រើប្រាស់បន្ទាន់ពី FDA សម្រាប់មនុស្សចាប់ពី 12 ឆ្នាំឡើងទៅ។ សូមមើលតារាងព័ត៌មានសង្ខេបសម្រាប់អ្នកទទួល និងអ្នកផ្តល់ការថែទាំសម្រាប់ព័ត៌មានបន្ថែម។

- **មនុស្សគ្រប់រូបដែលមានអាយុចាប់ពី 6 ខែឡើងទៅ** ត្រូវបានណែនាំអោយទទួលបានវ៉ាក់សាំង COVID-19 ឆ្នាំ 2024-2025 ដែលបានធ្វើបច្ចុប្បន្នភាពក្រោមការអនុញ្ញាត ឬត្រូវបានអនុម័តដោយ FDA តាមអាយុសមស្រប។
- **មនុស្សមួយចំនួន ដូចជាអ្នកដែលមានស្ថានភាពផ្នែកវេជ្ជសាស្ត្រ ឬកំពុងប្រើថ្នាំដែលប៉ះពាល់ដល់ប្រព័ន្ធភាពស៊ាំ** អាចទទួលបានវ៉ាក់សាំង COVID-19 ដូសបន្ថែម។ អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកអាចណែនាំអ្នកបាន.

U.S. CENTERS FOR DISEASE CONTROL AND PREVENTION

## 3. និយាយជាមួយអ្នកផ្ដល់សេវាថែទាំសុខភាពរបស់អ្នក

សូមប្រាប់អ្នកផ្ដល់ការចាក់វ៉ាក់សាំងរបស់អ្នក ប្រសិនបើបុគ្គលនោះទទួលវ៉ាក់សាំង៖

- ធ្លាប់មាន**ប្រតិកម្មអាឡែហ្សីបន្ទាប់ពីវ៉ាក់សាំង** COVID-19 **ដូសមុន** ឬមាន**អាឡែហ្សីធ្ងន់ធ្ងរដែលគំរាមកំហែងដល់អាយុជីវិត**
- មាន**ជំងឺរលាកសាច់ដុំបេះដូង** (រលាកសាច់ដុំរបស់បេះដូង) ឬ**រលាកស្រោមបេះដូង** (រលាកស្រទាប់ខាងក្រៅនៃបេះដូង)
- មាន**អាការៈរោគរលាកពហុប្រព័ន្ធ** (ហៅថា MIS-C ចំពោះកុមារ និង MIS-A ចំពោះមនុស្សពេញវ័យ)

ក្នុងករណីខ្លះ អ្នកផ្ដល់សេវាថែទាំសុខភាពរបស់អ្នកអាចសម្រេចចិត្តពន្យារពេលការចាក់វ៉ាក់សាំង COVID-19 រហូតដល់ការណាត់ជួបនាពេលខាងមុខ។

អ្នកដែលមានជំងឺស្រាល ដូចជាជំងឺផ្ដាសាយ អាចទទួលការចាក់វ៉ាក់សាំងនេះបាន។ អ្នកដែលមានជំងឺធ្ងន់ល្មម ឬធ្ងន់ធ្ងរខ្លាំង រួមទាំងជំងឺ COVID-19 ជាធម្មតាគួររង់ចាំរហូតដល់ពួកគេជាសះស្បើយសិន។

វ៉ាក់សាំង COVID-19 អាចចាក់ឲ្យក្នុងពេលដំណាលគ្នានឹងវ៉ាក់សាំងដទៃទៀត។

## 4. ហានិភ័យកើតប្រតិកម្មវ៉ាក់សាំង

- ការឈឺចាប់ ហើម ឬក្រហមនៅកន្លែងចាក់ថ្នាំ គ្រុនក្ដៅ អស់កម្លាំង (អស់កម្លាំង) ឈឺក្បាល ញាក់ ឈឺសាច់ដុំ ឈឺសន្លាក់ ចង្អោរ ក្អួត និងហើមកូនកណ្ដុរអាចកើតឡើង បន្ទាប់ពីចាក់វ៉ាក់សាំង COVID-19។
- ជំងឺរលាកសាច់ដុំបេះដូង (រលាកសាច់ដុំបេះដូង) និងរលាកស្រោមបេះដូង (រលាកស្រទាប់ខាងក្រៅបេះដូង) កម្រត្រូវបានគេឃើញណាស់បន្ទាប់ពីចាក់វ៉ាក់សាំង COVID-19។ ហានិភ័យទាំងនេះត្រូវបានគេសង្កេតឃើញញឹកញាប់បំផុតចំពោះបុរសពេញវ័យ និងក្មេងប្រុសវ័យជំទង់។ ឱកាសនៃការកើតឡើងនេះគឺទាប។

ពេលខ្លះ មនុស្សអាចសន្លប់ បន្ទាប់ពីដំណើរការវេជ្ជសាស្ត្ររួមទាំងការចាក់វ៉ាក់សាំង។ សូមប្រាប់អ្នកផ្ដល់សេវាថែទាំសុខភាពរបស់អ្នក ប្រសិនបើអ្នកវិលមុខ ឬចក្ខុញ្ញាណផ្លាស់ប្ដូរ ឬឮសំឡេងហឹងក្នុងត្រចៀក។

ដូចថ្នាំផ្សេងទៀតដែរ វ៉ាក់សាំងកម្រនឹងបង្កប្រតិកម្មអាលែហ្ស៊ីធ្ងន់ធ្ងរ របួសធ្ងន់ធ្ងរផ្សេងទៀត ឬធ្វើឲ្យស្លាប់បាត់បង់ជីវិតណាស់។

V-Safe គឺជាប្រព័ន្ធត្រួតពិនិត្យសុវត្ថិភាពដែលអនុញ្ញាតឱ្យអ្នកចែករំលែកជាមួយ CDC អំពីសភាពរបស់អ្នក ឬអ្នកនៅក្នុងបន្ទុករបស់អ្នកបន្ទាប់ពីទទួលវ៉ាក់សាំង COVID-19។ អ្នកអាចស្វែងរកព័ត៌មាន និងចុះឈ្មោះក្នុង V-Safe តាមអាសយដ្ឋាន vsafe.cdc.gov។

## 5. ចុះបើមានបញ្ហាធ្ងន់ធ្ងរ?

ប្រតិកម្មអាលែហ្សីអាចកើតឡើង បន្ទាប់ពីអ្នកទទួលការចាក់វ៉ាក់សាំងចាកចេញពីគ្លីនិក។ ប្រសិនបើអ្នកឃើញសញ្ញានៃប្រតិកម្មអាឡែហ្សីធ្ងន់ធ្ងរ (កន្ទួលក្រហម ហើមមុខ និងបំពង់ក ពិបាកដកដង្ហើម បេះដូងលោតញាប់ វិលមុខ ឬខ្សោយ) សូមទូរសព្ទទៅ **9-1-1** ហើយនាំអ្នកជំងឺទៅមន្ទីរពេទ្យដែលនៅជិតបំផុត។

ស្វែងរកការព្យាបាលភ្លាមៗ ប្រសិនបើអ្នកដែលទទួលវ៉ាក់សាំងមានការឈឺទ្រូង ដង្ហក់ ឬមានអារម្មណ៍ថាបេះដូងលោតញាប់ ញ័រ បន្ទាប់ពីចាក់វ៉ាក់សាំង COVID-19។ ទាំងនេះអាចជារោគសញ្ញានៃជំងឺរលាកសាច់ដុំបេះដូង ឬរលាកស្រោមបេះដូង។

សម្រាប់សញ្ញាផ្សេងទៀតដែលធ្វើឱ្យអ្នកបារម្ភ សូមទូរសព្ទទៅអ្នកផ្ដល់សេវា ថែទាំសុខភាពរបស់អ្នក។

ប្រតិកម្មអាក្រក់គួរតែត្រូវបានរាយការណ៍ទៅប្រព័ន្ធរាយការណ៍ព្រឹត្តិការណ៍អាក្រក់កើតចេញវ៉ាក់សាំង Vaccine Adverse Event Reporting System (VAERS)។ អ្នកផ្ដល់សេវាថែទាំសុខភាពរបស់អ្នកជាធម្មតានឹងដាក់របាយការណ៍នេះ ឬអ្នកអាចធ្វើវាដោយខ្លួនឯងបាន។ សូមចូលទៅគេហទំព័រប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំវ៉ាក់សាំង (VAERS) www.vaers.hhs.gov ឬទូរសព្ទទៅលេខ **1-800-822-7967**។ *ប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំ (VAERS) សម្រាប់តែការរាយការណ៍អំពីប្រតិកម្ម ហើយបុគ្គលិករបស់ប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំ (VAERS) មិនផ្ដល់ដំបូន្មានអំពីវេជ្ជសាស្ត្រទេ។*

## 6. Countermeasures Injury Compensation Program (កម្មវិធីផ្ដល់សំណងការរងរបួសវិធានទប់ស្កាត់)

កម្មវិធី Countermeasures Injury Compensation Program (CICP) គឺជាកម្មវិធីសហព័ន្ធដែលអាចជួយបង់ប្រាក់សម្រាប់ការថែទាំវេជ្ជសាស្ត្រ និងការចំណាយជាក់លាក់ផ្សេងទៀតរបស់មនុស្សមួយចំនួនដែលរងរបួសធ្ងន់ធ្ងរដោយសារវ៉ាក់សាំង ឬឱសថមួយចំនួន រួមទាំងវ៉ាក់សាំងនេះ។ ជាទូទៅ ការទាមទារត្រូវតែដាក់ជូន CICP ក្នុងរយៈពេលមួយ (1) ឆ្នាំគិតចាប់ពីថ្ងៃទទួលវ៉ាក់សាំង។ ដើម្បីស្វែងយល់បន្ថែមអំពីកម្មវិធីនេះ សូមចូលទៅកាន់គេហទំព័ររបស់កម្មវិធីតាមអាសយដ្ឋាន www.hrsa.gov/cicp, ឬទូរសព្ទទៅលេខ **1-855-266-2427**។

## 7. តើខ្ញុំអាចស្វែងយល់បន្ថែមទៀតដោយរបៀបណា?

- សូមសួរអ្នកផ្ដល់សេវាថែទាំសុខភាពរបស់អ្នក។
- សូមទូរសព្ទទៅក្រសួងសុខាភិបាលរដ្ឋ ឬនៅតាមមូលដ្ឋានរបស់អ្នក។
- ចូលមើលគេហទំព័ររបស់រដ្ឋបាលចំណីអាហារ និងឱសថ (FDA) សម្រាប់សន្លឹកព័ត៌មានអំពី COVID-19 ការបញ្ចូលកញ្ចប់ និងព័ត៌មានបន្ថែមតាមអាសយដ្ឋាន www.fda.gov/emergency-preparedness-and-response/coronavirus-disease-2019-covid-19/covid-19-vaccines។
- សូមទាក់ទងមជ្ឈមណ្ឌលសម្រាប់ការគ្រប់គ្រង និងទប់ស្កាត់ជំងឺ (Centers for Disease Control and Prevention, CDC)៖
  - សូមទូរសព្ទទៅលេខ **1-800-232-4636** (**1-800-CDC-INFO**) ឬ
  - ចូលមើលគេហទំព័រវ៉ាក់សាំង COVID-19 របស់ CDC តាមអាសយដ្ឋាន www.cdc.gov/covid/vaccines/index.html។

Khmer translation provided by Immunize.org